ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

ឯកសារដើម
ORIGINAL/ORIGINAL
ថ្ងៃ ខែ ឆ្នាំ (Date): 20-Apr-2012, 15:03
CMS/CFO: Sann Rada

# កំណត់ហេតុជាលាយលក្ខណ៍អក្សរនៃកិច្ចដំណើរការនីតិវិធី
# ជំនុំជម្រះក្ដីនៅដំណាក់កាលដំបូង
## សាធារណៈ

សំណុំរឿងលេខ ០០២/១៩-០៩-២០០៧/អវតក/អជសដ

**ថ្ងៃទី២០ ខែមេសា ឆ្នាំ២០១២**

**ម៉ោង ០៩:០៤ នាទី**

**សវនាការលើកទី៥៣**

**ចៅក្រមសាលាដំបូង៖**

ចៅក្រម និល ណុន ជាប្រធាន
ចៅក្រម ស៊ីលវៀ ខាតរ៉ាយថ៍
*(Judge Silvia CARTWRIGHT)*
ចៅក្រម យ៉ា សុខន
ចៅក្រម ហ្សង់ម៉ាក ឡាវែន៍
*(Judge Jean-Marc LAVERGNE)*
ចៅក្រម យូរ ឧត្តរា
ចៅក្រម ធូ មណី (បម្រុង)
ចៅក្រម ក្លូឌា ហ្វេនស៍ (បម្រុង)
*(Judge Claudia FENZ)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក ឌុច ផារី
លោក ដាវ អានសាន
កញ្ញា ណាតាចា វីស៊ែល រីសឺ
*(Ms. Natacha WEXELS-RISER)*

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក សេង ប៊ុនឃាង
លោក ថារីក អាប់ឌុលឡាក់
*(Mr. Tarik ABDULHAK)*
លោក ដេល លីសាក់
*(Mr. Dale LYSAK)*

**ជនជាប់ចោទ៖**

លោក នួន ជា
លោក ខៀវ សំផន
លោក អៀង សារី

**មេធាវីការពារជនជាប់ចោទ នួន ជា៖**

លោក សុន អរុណ

លោក ហ្សាស្ពឺ ប៉ៅ*(Mr Jasper PAUW)*

លោក អេនឌ្រូ អ៊ីនូហ្ស៊ី

*(Mr. Andrew IANUZZI)*

**មេធាវីការពារជនជាប់ចោទ ខៀវ សំផន៖**

លោក គង់ សំអុន

លោកស្រី អង់តា ហ្គីសសេ

*(Ms. Anta GUISSÉ)*

**មេធាវីការពារជនជាប់ចោទ អៀង សារី៖**

លោក អាង ឧត្តម

លោក ម៉ៃខល កាណាវ៉ាស

*(Mr.Michael KARNAVAS)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ពេជ អង្គ

លោកស្រី អេលីហ្សាបេត ស៊ីម៉ូនណូហ្វត

*(Ms. Elisabeth SIMONNEAU-FORT)*

លោកស្រី ទី ស្រីនណា

លោក ហុង គឹមសួន

លោក បាណាបេ ណេគួ

*(Mr. Barnabé NEKUIE)*

លោកស្រី អេលីហ្សាប៊ែត រ៉ាបេសាន់ដ្រាតាណា

*(Ms. Elisabeth RABESANDRATANA)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក អ៊ុច អរុណ

# បញ្ជីឈ្មោះអ្នកនិយាយ៖

ភាសាដែលបានប្រើ លើកលែងតែមានការបញ្ជាក់ផ្សេងទៀតនៅក្នុងប្រតិចារឹក

| អ្នកនិយាយ | ភាសា |
|---|---|
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំ) | ខ្មែរ |
| លោក ខេល លីសាក់ | អង់គ្លេស |
| លោក សុន អរុណ | ខ្មែរ |
| លោក អាង ឧត្តម | ខ្មែរ |
| លោក គង់ សំអុន | ខ្មែរ |
| លោក ពេជ អង្គ | ខ្មែរ |
| លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត | បារាំង |
| លោក សូត្រ ទឿង (TCW-617) | ខ្មែរ |

## ឧបសម្ព័ន្ធ

**ការសួរសំណួរទៅសាក្សី: លោក សុត្រ ឡើង** (TCW-617)

សួរដោយលោក សុន អរុណ ផ្ដើមពី៖....................................................................ទំព័រ០២

សួរដោយលោក អាង ឧត្ដម ផ្ដើមពី៖ ..................................................................ទំព័រ០៨

# កិច្ចដំណើរការនីតិវិធី

*(ចៅក្រមចូលក្នុងបន្ទប់សវនាការ)*

[០៩:០៤:០៥]

**ប្រធានអង្គជំនុំ៖**

អង្គុយចុះ!

អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ។ នៅក្នុងសវនាការថ្ងៃនេះ គឺនឹងដំណើរការពិភាក្សាដេញដោលដោយការតាំងសំណួរពីក្រុមមេធាវីការពារក្តីលោក ខៀវ សំផន និងក្រុមមេធាវីការពារក្តីលោក អៀង សារី ចំពោះសាក្សី សួត្រ ឡើង។

សូមអញ្ជើញលោកមេធាវីការពារក្តីលោក នួន ជា!

**លោក សុន អរុណ៖**

សូមគោរពអង្គសវនាការ សូមគោរពលោកប្រធាន។ ដោយពីម្សិលមិញ សហការីរបស់ខ្ញុំបានធ្វើសំណួរអស់រយៈជិតមួយម៉ោង។ ខ្ញុំយល់ថា ខ្ញុំនៅមានសំណួរខ្លះ សម្រាប់សួរទៅ ឡើង ប្រហែលជា ១៥ ទៅ២០នាទី ប្រសិនតុលាការអនុញ្ញាត ខ្ញុំនឹងសុំព្រឹកនេះ នាពេលឥឡូវនេះសួរប្រហែលជា១៥នាទីទៅ២០នាទីប៉ុណ្ណឹង។ សូមអរគុណ។

[០៩:០៥:៣៥]

**ប្រធានអង្គជំនុំ៖**

បាទ អង្គ-- សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

ជម្រាបសួរលោកប្រធាន ជម្រាបសួរលោក លោកស្រីចៅក្រម ជម្រាបសួរភាគីទាំងអស់។ ខ្ញុំមើលឃើញថា សាក្សីនេះ អត់មានមេធាវីជំនួយទេ។ ខ្ញុំគ្រាន់តែចង់ដឹងច្បាស់ថា តើគាត់បដិសេធមិនព្រមយកមេធាវី ឬក៏យ៉ាងណា? បើមិនអ៊ីចឹងទេ ខ្ញុំគិតថាសូមមេត្តាឲ្យមានវត្តមានមេធាវីនៅចំពោះ--នៅជិតគាត់។ សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

អង្គជំនុំជម្រះសម្រេចអនុញ្ញាតតាមការស្នើសុំរបស់មេធាវីជាតិការពារក្តី នួន ជា នៅក្នុងការបន្តការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ រយៈពេល១៥ ឬក៏២០នាទីទៀត។

លោក សូត្រ ទៀង នៅពេលនេះ អង្គជំនុំជម្រះសង្កេតឃើញថា លោកអត់មានមេធាវីអមដូចកាលពីម្សិលមិញទេ។ តើលោកអាចឆ្លើយទៅនឹងសំណួរដែលនឹងសួរលោកនៅព្រឹកនេះ ដោយមិនចាំបាច់មានមេធាវីអមទេ? ពីព្រោះអង្គជំនុំជម្រះក៏កត់សម្គាល់ឃើញដែរ ថារយៈកាលពីរថ្ងៃមក ដែលមានមេធាវីអមហ្នឹង ក៏ដូចជាលោកអាចម្ចាស់ការបានដោយខ្លួនឯង ក្នុងការឆ្លើយតបទៅនឹងសំណួរ។

តើឥឡូវនេះ លោកយ៉ាងម៉េចដែរ? អាចឆ្លើយនឹងសំណួរបានដែរទេ?

[០៩:០៧:០៥]

**លោក សូត្រ ទៀង៖**

សំណួរណាឆ្លើយបានៗ សំណួរណាឆ្លើយមិនបាន គឺអត់ តាមមើលតទៅទៀត។

**ប្រធានអង្គជំនុំ៖**

អ៊ីចឹងមានន័យថា មិនចាំបាច់មានមេធាវីអម ដូចម្សិលមិញទេ មែនទេ?

**លោក សូត្រ ទៀង៖**

មិនចាំបាច់ក៏បានដែរ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ ហើយមន្ត្រីរដ្ឋបាលតុលាការទៅសម្រួលនូវក្បាលមីក្រូហ្វូនហ្នឹង ធ្វើម៉េចឲ្យខ្ញុំបានមើលឃើញ។ អឺ! អូខេ។ អាចៗរុញកុំព្យូទ័រមកៗខាងលិច មកៗលិចបន្តិចមក។ អូខេ។

[០៩:០៨:១៤]

អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅមេធាវីជាតិការពារក្តីលោក នួន ជា។ សូមអញ្ជើញ!

**ការតាំងសំណួរដោយសហមេធាវីការពារក្តី**

**សួរដោយលោក សុន អរុណ៖**

លោក សូត្រ ទៀង ខ្ញុំជាមេធាវីរបស់លោក នួន ជា។ ខ្ញុំមានសល់សំណួរ-- ក្រុមខ្ញុំមានសល់ប្រហែលជាបីបួនតែប៉ុណ្ណឹងទេ ប្រហែលជា១៥ ទៅ២០នាទី។

**ស៖** ជាដំបូង ខ្ញុំសូមសួរថា លោក ទៀង បានធ្វើការជាមួយលោក នួន ជា ជិតដិតជាមួយលោក នួន ជា ហ្នឹង រយៈពេលប៉ុន្មាន?

**លោក សូត្រ ទៀង៖**

**ឆ៖** តាំងពី៧៥ ដល់៧៧ រហូតដល់៧៨។ ប៉ុន្តែខ្ញុំអត់ចាំដែរ ខ្ញុំចាំប៉ុណ្ណឹង។

**ស៖** សូមអរគុណណ៎ា។ លោកស្គាល់លោក នួន ជា ច្បាស់លាស់ បើខ្ញុំតាមមើលក្នុងប្រវត្តិរូបមក ពីព្រោះអីលោកបានធ្វើការជិតដិតជាមួយលោក នួន ជា។ លោកអាចសម្គាល់បានថា លោក នួន ជា ជាមនុស្សម្នាក់ ជាមេដឹកនាំម្នាក់ មានចិត្តឃោរឃៅ កាចសាហាវ ឬក៏ស្លូតបូត ឬក៏ចូលចិត្តអប់រំមនុស្សឲ្យទៅជាល្អ?

[០៩:០៩:៤៧]

**ធ៖** ពេលដែលគាត់ដឹកនាំ មិនមែនសាហាវទេ គឺល្អ ត្រឹមត្រូវដែរ ប៉ុន្តែក្រៅពីនោះ ខ្ញុំអត់ដឹងដែរ។ អប់រំក៏ល្អដែរ អប់រំប្រជាជន មហាជនល្អ បាទ។

**ស៖** សូមអរគុណ។ លោកនៅជាមួយគាត់ជិតដិតសឹងតែរាល់ពេល លោកមានដែលឮគេនិយាយខាងក្រៅ ឬក៏ឮពីអ្នកជិតដិតជាមួយគាត់ហ្នឹង ប្រាប់លោក ទៀង ថា គាត់មានដែលបញ្ជូនមនុស្សទៅគុក ស-២១ ឲ្យ ឌុច ទេ?

**ធ៖** ខ្ញុំអត់ដែលឮ អត់ដែលឃើញ អត់ដឹងទេ។

**ស៖** ឮថាម៉េច?

**ធ៖** អត់ដែលឮទេ អត់ដែលដឹងទេបាទ។

[០៩:១០:៤៤]

**ស៖** សូមអរគុណណាស់។ ពីម្សិលមិញ ទាំងព្រះរាជអាជ្ញា ទាំងមេធាវីដើមបណ្ដឹងរដ្ឋប្បវេណី ព្រមទាំងមេធាវីសហការីខ្ញុំបានសួរលោកមួយចំនួនរួចទៅហើយ។ ប៉ុន្តែខ្ញុំនឹងសូមរំឭកឡើងវិញ ហើយខ្ញុំចង់សួរនិងបញ្ជាក់ម្ដងទៀត សូមឲ្យលោកឆ្លើយម្ដងសាជាថ្មីម្ដងទៀត។ អំពីសម្បថរបស់លោកជាមួយនឹងចៅក្រមស៊ើបអង្កេត លោកនៅចាំហើយ ពេលដែលចៅក្រមស៊ើបអង្កេតអញ្ជើញលោកមកសួរចម្លើយ លោកបានស្បថ មិនអីចឹង?

**ធ៖** បាទ បានស្បថតាមគេបញ្ជា។

**ស៖** ពេលដែលស្បថហ្នឹងលោក លោកស្បថដោយសុទ្ធចិត្តខ្លួនឯង ឬក៏ស្បថដោយគេប្រាប់ថាឲ្យថាម៉េចៗ?

**ធ៖** បាទ ស្បថហ្នឹងគឺស្បថតាម បើគិតទៅយល់ ក៏មិនទាន់យល់ដែរ បានថា គិតទៅតាមថាស្បថតាមដែលគេកំណត់ក្នុងសៀវភៅហ្នឹង បើមិនស្បថតាមហ្នឹង គាត់ថាវាមិនចប់ទេដោះស្រាយទៅ បើតាមហ្នឹងបានចប់ ដោះស្រាយទៅបានបាទ។

[០៩:១២:២២]

**ស៖** លោកបញ្ជាក់បន្តិចទៀតមើល ស្បថតាមហ្នឹង ស្បថយ៉ាងម៉េច?

**ឆ៖** ព្រោះកន្លែងហ្នឹងខ្ញុំអត់យល់ដែរ បាទ។

**ស៖** ពេលស្បថហ្នឹងគេបង្ខំឲ្យលោកស្បថ ឬក៏លោកស្បថដោយចិត្តខ្លួនឯង ដោយគ្រាន់តែគេប្រាប់ថាឲ្យស្បថ ហើយលោកនិយាយដោយគ្មានការបង្ខំ?

**ឆ៖** បាទ អត់បង្ខំទេ គ្រាន់តែគាត់ប្រាប់ថា ស្បថតាមខ្លឹមសារក្រដាសហ្នឹងបាទ។

**ស៖** អរគុណ។ បើអ៊ីចឹងគេមានក្រដាសមួយសរសេរសម្បថហើយស្រេច ហើយឲ្យលោកអានអ៊ីចឹង?

**ឆ៖** *(សាក្សីនិយាយមិនបើកក្បាលមីក្រូ)*។

**ស៖** សូម-- គេមានក្រដាសមួយសរសេរពាក្យសម្បថហើយស្រេច ហើយឲ្យលោកអានតាមក្រដាសហ្នឹង ឬក៏គេអានឲ្យលោកថាតាមអ៊ីចឹងអី ឬយ៉ាងម៉េច?

**ឆ៖** គេអានឲ្យ។

[០៩:១៣:៣៨]

**ស៖** បាទ បើអ៊ីចឹងទេ ន័យនៃពាក្យសម្បថរបស់លោក ដែលគេអានឲ្យ ហើយលោកថាតាមហ្នឹង លោកអត់យល់អីទាំងអស់ អ៊ីចឹង? លោកមិនយល់ទេពាក្យសម្បថហ្នឹង? ថាតាមតែគេប្រាប់អ៊ីចឹង?

**ឆ៖** បាទ ខ្ញុំមិនយល់ដែរ។ បើអ៊ីចឹង-- បានន័យថាមិនយល់ បានន័យថាមិនឆ្លើយថាចេះ។ អ៊ំា ឧទាហរណ៍ឥឡូវចាប់ពីថ្ងៃនេះទៅ ខ្ញុំឈប់សម្លាប់មនុស្ស ខ្ញុំឈប់ធ្វើបាបមនុស្ស។ ដល់អ៊ីចឹង ខ្ញុំចេះតែឆ្ងល់សង្ស័យទៅ បើខ្ញុំអត់សម្លាប់មនុស្ស មកស្បថអ៊ីចឹងដូចមិនត្រូវទេ អ្នកណាបង្កើតអាន់ុង។ ទាល់ពីរដងបីដង បានប៊ានស្បថតាមក្រដាសនុ៎ងបាន។

**ស៖** សូមអរគុណណាស់។ បើអ៊ីចឹង ខ្ញុំមិនមែនសន្និដ្ឋានទេ បើអ៊ីចឹងមានន័យថា លោកស្បថនេះក្នុងន័យមួយដែលគេបង្គាប់ឲ្យលោកស្បថ ឲ្យថាតាមគេ។ លោកយល់សំណួរខ្ញុំទេ? អាហ្នឹងខ្ញុំចង់សួរថា បើអ៊ីចឹងលោកស្បថហ្នឹង លោកអត់យល់ន័យពាក្យសម្បថហ្នឹងទេ គឺលោកថាតាមតុលាការដែលគេឲ្យលោកស្បថ ថាតាមគេ ក្រដាសដែលគេសរសេរហើយ អ៊ីចឹងណ៎ា! អ៊ីចឹង ឬយ៉ាងម៉េច?

**ឆ៖** អ៊ីចឹងឯង ព្រោះអត់ទាន់យល់។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកស្រីមេធាវី!

**លោកស្រី អេលីហ្សាបេត ស៊ីម៉ុនណូហ្វត៖**

លោកប្រធាន ខ្ញុំកំពុងតែរង់ចាំការបកប្រែជាភាសាបារាំង ដែលមកជាមួយនឹងចម្លើយរបស់សាក្សី ប៉ុន្តែខ្ញុំសូមជំទាស់ទៅនឹងសំណួរនេះ ដូចដែលមុនដែរ វាជាសំណួរដែលនាំមុខ ដែលណែនាំសាក្សីឱ្យឆ្លើយ។ ដូច្នេះមិនត្រូវសួរសំណួរបែបនេះទេ។ ខ្ញុំសោកស្តាយណាស់ ដែលមានទទួលបានការបកប្រែរាងយឺតបន្តិច។ ប៉ុន្តែខ្ញុំមិនគិតថា វាជាកំហុសរបស់អ្នកប្រែនោះទេ។

[០៩:១៦:០៣]

**ប្រធានអង្គជំនុំ៖**

លោកមេធាវី សូមលោកយល់អំពីនីតិវិធីតុលាការ គឺពាក្យសម្បថដែលមានចែងនៅក្នុងក្រមស្តីពីនីតិវិធីព្រហ្មទណ្ឌ ដែលតម្រូវឱ្យមន្ត្រីតុលាការ គឺក្រឡាបញ្ជីជាអ្នកទទួលខុសត្រូវនៅក្នុងការណែនាំដល់សាក្សីក្នុងការធ្វើសម្បថ ហើយខ្លឹមសារដែលមានចែងនៅក្នុងច្បាប់ នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះត្រូវដកស្រង់ទាំងស្រុងយកទៅឱ្យសាក្សីអាន ហើយដោយខ្លួនឯង នៅក្នុងការករណីសាក្សីហ្នឹងគាត់ចេះអក្សរ ចេះអាន។ ក្នុងករណីមិនចេះអានទេ ក្រឡាបញ្ជីមានកាតព្វកិច្ចក្នុងការអាននូវខ្លឹមសារនៃពាក្យសម្បថដែលចែងក្នុងច្បាប់ ឱ្យសាក្សីថាតាម មិនខុសគ្នាអ្វីពីអ្នកដែលបានធ្វើសច្ចាប្រណិធាននៅចំពោះមុខអង្គជំនុំជម្រះ ដែលកាន់សាសនាផ្សេងៗ ដែលបានធ្វើកន្លងមកទេ សុទ្ធតែបានសរសេរជាក្រដាសរួចជាស្រេច ហើយឱ្យថាតាម ឬក៏អានតាមការកំណត់របស់ក្រឡាបញ្ជី ដែលណែនាំអំពីនីតិវិធីធ្វើសម្បថ។

លោកអាចតាំងសំណួរផ្សេងទៀតបាន សំណួរពាក់ព័ន្ធនឹងសម្បថនេះ ទំនងជាមិនអាចសួរដេញដោលរបៀបនេះបានទេ។

**លោក សុន អរុណ៖**

សូមអរគុណលោកប្រធាន។ ខ្ញុំនឹងបន្តទៅសំណួរទីពីរ។

[០៩:១៧:៤០]

**សួរដោយលោក សុន អរុណ៖**

**ស៖** លោក ទៀង ខ្ញុំសូមសួរនូវសំណួរទីពីរ។ ពីម្សិលមិញលោកបានឆ្លើយជាមួយនឹងសហព្រះរាជអាជ្ញា ឬជាមួយនឹងមេធាវីការពារជនរងគ្រោះ លោកថា លោកឆ្លើយថា “ជូនកាលលោកបានយក

លិខិតពីលោកនួន ជា ទៅឲ្យឌុច ពីពីរទៅបីដង"។ ជួនកាលលោកឆ្លើយថា ឆ្លើយពេលខុសគ្នា ដោយគេសួរដដែលៗពេក ជួនកាលលោកឆ្លើយថា "ប្អូនទៅប្រាំដង"។ ជួនកាលលោកឆ្លើយថា "អត់មានយកទេ"។ ថ្ងៃនេះក្នុងការសង្ស័យរបស់ខ្ញុំ ខ្ញុំសូមឲ្យលោកឆ្លើយម្តងទៀត បញ្ជាក់មួយម៉ាត់ឲ្យច្បាស់ថា មាន ឬក៏មិនមាន? ហើយបើមានបានប៉ុន្មានដង?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកតំណាងសហព្រះរាជអាជ្ញាអន្តរជាតិ!

**លោក ឌេល លីសាក់៖**

លោកប្រធាន នេះជាសំណួរនាំមុខ ពីព្រោះថា ដែលថា គាត់នាំមុខដោយមិនតាមពាក្យសម្តីត្រឹមត្រូវរបស់សាក្សីទេ។ អ្វីដែលសាក្សីនិយាយពីម្សិលមិញនេះ គាត់ឆ្លើយស្របគ្នា ហើយគាត់ថា គាត់បានបញ្ជូនទៅបញ្ជូនមក ហើយគាត់ឆ្លើយទៀងទាត់។ អ៊ីចឹងហើយ លោកមេធាវីគាត់ស្រង់ពាក្យមកដូចជាមិនដូចសម្តីដែលសាក្សីបានឆ្លើយទេលោកប្រធាន។

**លោក សុន អរុណ៖**

ខ្ញុំសូមឆ្លើយទៅសហព្រះរាជអាជ្ញា។ ខ្ញុំបានកត់ទុកពីម្សិល ហើយដល់ព្រលឹមឡើងនេះ ខ្ញុំរកមើល *ត្រេនស្ក្រីប* នៅក្នុងកុំព្យូទ័រអត់មាន ខ្ញុំចង់មើលសាឡើងវិញមានឆ្លើយប៉ុន្មានដង។ ប៉ុន្តែខ្ញុំបានកត់ទុករឿងហ្នឹង។ អ៊ីចឹងហើយបានខ្ញុំចង់បញ្ជាក់ ថាតើរឿងហ្នឹងពិតយ៉ាងម៉េច? ការពិត ដើម្បីៗឲ្យសាក្សីដែលអ្នកជិតដិតជាមួយគាត់ហ្នឹងបញ្ជាក់ប្រាប់តុលាការថា រឿងនេះ ពិតយ៉ាងម៉េច។ អានេះការខ្ញុំចង់ដឹង។ សូមអស់។

**ប្រធានអង្គជំនុំ៖**

ជំទាស់មានប្រសិទ្ធភាព។ សំណួរច្រំដែល ហើយនិងសំណួរដឹកមុខ។ សាក្សីមិនបាច់ឆ្លើយតបនឹងសំណួរនេះទេ!

[០៩:២០:២៦]

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំសូមសួរបន្តទៅទៀត។ ពេលដែល ឌុច-- ពេលដែលលោក ទៀង បានយកសំបុត្រពី នួន ជា ទៅឲ្យ ឌុច តើលោកយកផ្ទាល់ពី នួន ជា ឬក៏យកបន្តពីអ្នកណាម្នាក់? ទទួលសំបុត្រហ្នឹងណាបន្តពីអ្នកណាម្នាក់ ឬទទួលសំបុត្រពី នួន ជា ផ្ទាល់?

**លោក សូត្រ ទឿង៖**

**ឆ៖** ពេលខ្លះតាមតា នួន ជា ពេលខ្លះតាម ប៉ង់ ពីរនាក់ហ្នឹង បាទ។

**ស៖** អរគុណ។ ចុះដល់ពេលយកទៅឲ្យ ឌុច នោះ យកទៅឲ្យ ឌុច ផ្ទាល់ ឬក៏ឲ្យ យកត្រឹមណា? ត្រឹមទ្វារ ឬក៏ឲ្យអ្នកណា ហើយបន្តទៅឲ្យ ឌុច?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវី!

**លោក ពេជ អង្គ៖**

សូមគោរពលោក លោកស្រីចៅក្រម អង្គសវនាការទាំងមូល សាធារណជន លោកប្រធាន។ សំណួរមុនហ្នឹង ហើយនិងសំណួរនេះ ក៏ជាសំណួរច្រំដែល ដែលត្រូវបានលើករួចហើយតាំងពីថ្ងៃដំបូងមកម្ល៉េះ។ ខ្ញុំសូមលោកប្រធានជួយណែនាំ។ សូមអរគុណ។

[០៩:២១:៤៣]

**ប្រធានអង្គជំនុំ៖**

សាក្សី-- សូមអញ្ជើញៗលោកមេធាវី! បើកក្បាលមីក្រូសិន!

**លោក សុន អរុណ៖**

ពីម្សិលមិញ មេធាវីលោកស្រីការពារខាងជនជាប់-- អ៊ំ ខាងជនរងគ្រោះ បាននិយាយច្រំដែលហ្នឹងច្រើនដងណាស់ មើលសំណួរដែលចៅក្រមសួរហើយហ្នឹងអ៊ែ្ល យកមកសួត្រ សួរសាក្សីច្រើនដងណាស់ ហើយខ្ញុំគ្រាន់តែធ្វើអ៊ីចឹងដដែល ខ្ញុំថា ដូចជាមិនខុសអីទេ។ សូមអត់ទោស។

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់របស់មេធាវីការពារក្តី អ៊ំ មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី មានប្រសិទ្ធភាពសំណួរច្រំដែល មិនអនុញ្ញាតឲ្យសាក្សីឆ្លើយទៀតទេ។

**សួរដោយលោក សុន អរុណ៖**

**ស៖** ខ្ញុំបន្តទៅសំណួរទីបី។ លោក សូត្រ ទឿង ថ្ងៃនេះលោកក្នុងឋានៈជាសាក្សី កាលពីលោកធ្វើការជាមួយនឹងលោក នួន ជា ក្នុងឋានៈជាកងការពារ ហើយនិងអ្នកនាំសារអ៊ីចឹងទៅ តើលោកដែលឮឈ្មោះ សុន សេន ទេ?

**ឆ៖** ឮបាទ។

**ស៖** លោកបានធ្វើអ្វី? លោកមានមុខងារជាអ្វីលោក សុន សេន?

**ឆ៖** ខ្ញុំអត់សួរចាំដែរ មិនដឹងខាងអី មិនដឹងដែរ។

**លោក សុន អរុណ៖**

ខ្ញុំដូចជាមិនមានសំណួរអីតទៅទៀតទេ មានតែប៉ុណ្ណឹង បីសំណួរប៉ុណ្ណឹង។ សូមអរគុណលោកប្រធាន។

[០៩:២៣:៣២]

**ប្រធានអង្គជំនុំ៖**

បាទ អរគុណលោកមេធាវី។ ជាកិច្ចបន្ត អង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី ខៀវ សំផន ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។

**លោក គង់ សំអុន៖**

សូមអរគុណលោកប្រធាន។ ដោយសារកន្លងមក ខ្ញុំអត់ឃើញមានបញ្ហាអីទាក់ទងដូចជាការដាក់បន្ទុកចំពោះលោក ខៀវ សំផន ទេ ដូច្នេះយើងខ្ញុំពុំមានសំណួរចំពោះសាក្សីនេះទេ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ ជាបន្តអង្គជំនុំជម្រះសូមផ្តល់វេទិកាជូនទៅក្រុមមេធាវីការពារក្តី លោក អៀង សារី ដើម្បីមានឱកាសក្នុងការតាំងសំណួរដេញដោលចំពោះសាក្សីរូបនេះ។ សូមអញ្ជើញ!

**លោក អាង ឧត្តម៖**

ជាបឋមសូមគោរពលោកប្រធាន លោក លោកស្រីចៅក្រម។ សូមគោរពអង្គសវនាការ។ សួស្តីលោក លោកស្រី ដែលបានចូលរួមសវនាការនេះ នៅក្នុងបន្ទប់ ឬនៅក្រៅបន្ទប់ ហើយក៏សូមសួស្តីផងដែរលោក សូត្រ ទើង។ ខ្ញុំ អាង ឧត្តម ជាសហមេធាវីជាតិការពារក្តី លោក អៀង សារី នៅពេលនេះខ្ញុំមានសំណួរមួយចំនួនតូច ហើយក៏សំណួរខ្លីៗទេ ដែលសុំពិភាក្សាជាមួយលោកនៅថ្ងៃនេះ។

**សួរដោយលោក អាង ឧត្តម៖**

**ស៖** ទីមួយ ខ្ញុំចង់ពិភាក្សាជាមួយលោកទាក់ទងរឿងការងារសន្តិសុខ ទីពីរ ការងារអង្គរក្ស ទីបី ការងារនីរសារ។ សំណួរខ្ញុំដំបូង ខ្ញុំចង់សួរថា-- ហើយលោកក៏បានបញ្ជាក់ដែលឡើងវិញថា លោកស្គាល់ យ១០ ៗ ជាអង្គភាពការពារសន្តិសុខមែនទេ?

**លោក ស្វូត្រ ទ្បើង៖**

**ឆ៖** បាទ សន្តិសុខហ្នឹង គឺការការពារមន្ទីរ៧១ ហ្នឹងឯង ខាងៗកងទ័ពនេះឯង ខាងទាហាន។ ត្រូវការទៅណា-- ដូចនិយាយខាងដើមហើយ បើនិយាយតទៅទៀត វាកាន់តែបែក វាមិនចំ។ សន្តិសុខការពារជុំវិញមន្ទីរ បាទ។

**សៈ** បាទ សូមអរគុណ។ ហើយលោកក៏ជាបុគ្គលិក ភ្នាក់ងារធ្វើការនៅអង្គភាព យ១០ ជាភ្នាក់ងារសន្តិសុខនុ៎ងហើយ មែនទេ?

**ឆ៖** ខ្ញុំ--

[០៩:២៦:៤០]

**ប្រធានអង្គជំនុំ៖**

សូមៗ អញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

សាក្សីកុំអាលឆ្លើយតប!

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន! លោកប្រធាន សូមជំទាស់ដោយសារជាសំណួរនាំមុខ។

សូមអរគុណលោកប្រធាន។

**ប្រធានអង្គជំនុំ៖**

សេចក្តីជំទាស់មានប្រសិទ្ធភាព មេធាវីអាចផ្លាស់ប្តូរនូវវិធីសាស្រ្តក្នុងការសួរ ធ្វើយ៉ាងកុំឱ្យទៅជាសំណួរប្រភេទដែលច្បាប់ហាមឃាត់។

**សួរដោយលោក អាង ឧត្តម៖**

**សៈ** នៅ ក១ និង ក៣ លោកមានតួនាទីជាអង្គរក្សការពារសន្តិសុខ អ៊ីចឹងមែនទេ?

[០៩:២៧:៤០]

**លោក ស្វូត្រ ទ្បើង៖**

**ឆ៖** មែន ជូន តាវន។

**សៈ** លោកការពារនៅខាងក្រៅអគារ ក១ ឬ/និង ក៣ ហ្នឹង មែនទេ?

**ឆ៖** មែន។

**សៈ** ខ្ញុំសូមឱ្យលោកពណ៌នាអំពីអគារ ក១ តើអគារ ក១ហ្នឹង មានប៉ុន្មានជាន់? សូមលោក--

**ឆ៖** បួនជាន់។

**ស៖** បួនជាន់។ ហើយអគារហ្នឹងមានរបងព័ទ្ធជុំវិញទេ?

**ឆ៖** មាន។

**ស៖** រីឯអគារ ក៣ វិញមានកម្ពស់ប៉ុន្មានជាន់?

**ឆ៖** មានមួយជាន់ ផ្ទះតូចៗ។

**ស៖** មួយជាន់ហ្នឹង-- សូមទោស ហើយអគារ ក៣ ដែលមានមួយជាន់ហ្នឹងមានជញ្ជាំងព័ទ្ធជុំវិញទេ? ខ្ញុំចង់និយាយរបងព័ទ្ធជុំវិញទេ? របងព័ទ្ធជុំវិញអគារហ្នឹង?

[០៩:២៩:១៤]

**ឆ៖** មាន ឃើញមាន។

**ស៖** ពេលប្រជុំម្តងៗ គេឲ្យលោកនៅយាមកន្លែងណា?

**ឆ៖** នៅក្រៅរបង។

**ស៖** ពីក្រៅរបងទៅ លោកអាចមើលឃើញទិដ្ឋភាពអីខ្លះនៅខាងក្នុង?

**ឆ៖** មើលមិនឃើញទេ ព្រោះជញ្ជាំងជិត។ ជញ្ជាំងថ្ម។

**ស៖** ហើយរបងអគារ ក១ និង ក៣ ហ្នឹងកម្ពស់ប្រហែលប៉ុន្មាន? របង?

**ឆ៖** ប្រហែលតែគ្នា។

**ស៖** ប្រហែលកម្ពស់?

**ឆ៖** បីម៉ែត្រហ្នឹង ពីរម៉ែត្រកន្លះ ប៉ុណ្ណឹង។

**ស៖** ទិដ្ឋភាពនៅខាងក្នុងអគារទាំងពីរនេះ តើលោកអាចមើលឃើញអ្វីខ្លះពីខាងក្រៅទៅ?

**ឆ៖** មើលអត់ឃើញទេ ព្រោះវាជិតហើយ។

**ស៖** សូមអរគុណ។ លោកធ្លាប់ដែលចូលរួមប្រជុំនៅក្នុង ក១ ឬ/និង អគារ ក៣ ទេ?

**ឆ៖** អត់ដែរទេ។

[០៩:៣១:៤៨]

**ស៖** នៅក្នុងបន្ទប់ប្រជុំនោះ លោកដឹងថា ថ្នាក់ដឹកនាំកម្មាភិបាលណាជួបថ្នាក់ដឹកនាំកម្មាភិបាលណានៅខាងក្នុងនុ៎ងទេ?

**ឆ៖** រឿងហ្នឹងខ្ញុំអត់ដឹងដែរ។

**ស៖** សូមអរគុណ។ លោកដឹងថានៅកិច្ចប្រជុំនុ៎ង បានឮថាគេប្រជុំពីរឿងអីទេ?

**ឆ៖** គេអត់ដែលប្រាប់យើងទេ ការងារគេ។

**ស៖** ខ្ញុំសូមបញ្ជាក់សំណួរនេះឡើងវិញថា លោកមិនបានដឹងថាអ្នកណាប្រជុំនៅខាងក្នុងនុ៎ងទេ មែនទេ?

**ឆ៖** បាទ។

**ស៖** ហើយលោកក៏មិនបានដឹងថា គេប្រជុំពីរឿងអីក្នុងអគារទាំងពីរហ្នឹងទេ មែនទេ?

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញលោកមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណី!

សាក្សីកុំអាលឆ្លើយតបនឹងសំណួរអម្បាញ់មិញនេះ!

[០៩:៣៤:០៨]

**លោក ពេជ អង្គ៖**

សូមគោរពលោកប្រធាន សូមគោរពអង្គសវនាការ។ នេះជាសំណួរនាំមុខ លោកប្រធាន។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

បាទអរគុណ។ សេចក្តីជំទាស់របស់មេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានប្រសិទ្ធភាព។ សាក្សីមិនបាច់ឆ្លើយតបទៅនឹងសំណួរដែលសួរចុងក្រោយដោយមេធាវីការពារក្តីលោក អៀង សារី អម្បាញ់មិញនេះទេ!

**សួរដោយលោក អាង ឧត្តម៖**

**ស៖** ខ្ញុំសូមចូលប្រធានបទមួយទៀត ទាក់ទងរឿងទំនាក់ទំនងរវាងលោក សួត្រ ទឿង និង លោក អៀង សារី។ ខ្ញុំសូមលោកពណ៌នាអំពីទំនាក់ទំនង ឬក៏ការទាក់ទងរវាងលោក សួត្រ ទឿង ផ្ទាល់ជាមួយនឹងលោក អៀង សារី តើមានខ្លះទេ? ហើយបើមាន យ៉ាងណាខ្លះ?

**លោក សួត្រ ទឿង៖**

**ឆ៖** ខ្ញុំអត់មានទាក់ទង ពាក់ព័ន្ធជាមួយតាំងពីមុនមក បាទ។

**ស៖** សូមអរគុណ។ តើលោកធ្វើជានីរសាររបស់លោក នួន ជា តើលោកធ្លាប់ដែលនាំសារលិខិត សំបុត្រអី ទៅឲ្យលោក អៀង សារី លោកស្រី អៀង ធីរិទ្ធ ឬលោក ខៀវ សំផន អីដែរទេ?

E1/65.1

**ឆ៖** អត់។

**ស៖** សូមអរគុណ។ ផ្ទុយទៅវិញ តើលោកធ្លាប់នាំសារ នាំលិខិត ឬសំបុត្រអី ពីលោក អៀង សារី ទៅអ្នកណា ឬកម្មាភិបាលណាផ្សេងទៀតទេ?

**ឆ៖** អត់មាន។

**លោក អាង ឧត្តម៖**

សូមអរគុណៗ។ ខ្ញុំអស់សំណួរហើយ ហើយតាំងនាមលោក អៀង សារី សហមេធាវីរបស់គាត់គឺលោក ម៉ៃខល កាណាវាស និងខ្ញុំ សូមអរគុណលោកច្រើន ដែលបានអញ្ជើញច្រើនមកផ្ដល់សក្ខីកម្មដើម្បីជួយតុលាការក្នុងការស្វែងរកការពិត និងយុត្តិធម៌ សូមលោកធ្វើដំណើរទៅវិញបានសុខសប្បាយតាមផ្លូវ។ សូមអរគុណលោកប្រធាន។

[០៩:៣៨:១០]

**ប្រធានអង្គជំនុំ៖**

បាទ ឥឡូវនេះ ឃើញថាកិច្ចដំណើរការពិភាក្សាដេញដោលចំពោះសាក្សីឈ្មោះ សូត្រ ទឿង ដោយក្រុមមេធាវីការពារក្ដី ដែលអង្គជំនុំជម្រះគ្រោងធ្វើពេញមួយព្រឹកមួយនេះ។ ឥឡូវនេះ ឃើញថាចប់បានមុនផែនការដែលតាមគ្រោងទុក។

ដូច្នេះ កិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះ គឺអង្គជំនុំជម្រះផ្អាកត្រឹមនេះ សវនាការលើកទៅបន្តធ្វើនៅថ្ងៃចន្ទ ទី២៣ ខែមេសា ឆ្នាំ២០១២ គឺសប្ដាហ៍ក្រោយចាប់ផ្ដើមពីម៉ោងប្រាំបួនព្រឹក។ ហើយទន្ទឹមនេះ ក៏សូមអង្គជំនុំជម្រះជូនដល់ភាគី និងសាធារណជនផងដែរ ថានៅសប្ដាហ៍ក្រោយនេះ គឺចាប់ពីថ្ងៃចន្ទ ទី២៣ ខែមេសា ឆ្នាំ២០១២ តទៅ សវនាការ គឺស្ដាប់សក្ខីកម្មដែលមានរហស្សនាម TCW-586 ដែលនឹងចាប់ផ្ដើមការតាំងសំណួរដេញដោលដោយសាក្សី-- ដេញដោលសាក្សីដោយតំណាងសហព្រះរាជអាជ្ញា មុនភាគីដទៃទៀតនៃរឿងក្ដី សូមជ្រាប។ ដូច-- អង្គជំនុំជម្រះប្រកាស-- អ៎! មុននឹងប្រកាសផ្អាក អង្គជំនុំជម្រះសូមថ្លែងអំណរគុណ ដល់លោក សូត្រ ទឿង ដែលបានលះបង់ពេលវេលាដ៏មានតម្លៃអញ្ជើញមកចូលរួមផ្ដល់សក្ខីកម្មនៅក្នុងកិច្ចដំណើរការសវនាការពេញពីរថ្ងៃកន្លះនេះ ហើយឃើញថាលោកខិតខំប្រឹងប្រែងអស់ពីលទ្ធភាពដែលមាន។

[០៩:៣៩:៥៣]

ហើយកិច្ចដំណើរការសវនាការនៃការស្ដាប់សក្ខីកម្មចំពោះរឿងក្ដីនេះ ដូចជាមិនមានភាពចាំបាច់

ទៀតទេ។ ដូច្នេះ លោកអាចវិលត្រឡប់ទៅកាន់លំនៅដ្ឋាន ឬក៏គោលដៅណាដែលលោកចង់ទៅបានហើយ។ សូមឲ្យមន្ត្រីរដ្ឋបាលតុលាការសម្របសម្រួលជាមួយនឹងខាងអង្គភាពគាំពារសាក្សី និងអ្នកជំនាញ ដើម្បីរៀបចំការធ្វើដំណើររបស់គាត់វិលត្រឡប់ទៅគោលដៅដែលគាត់ចង់ទៅវិញ។

អង្គជំនុំជម្រះប្រកាសផ្អាកកិច្ចដំណើរការសវនាការសម្រាប់ថ្ងៃនេះត្រឹមនេះ។ សវនាការលើកបន្តទៅធ្វើនៅថ្ងៃចន្ទ ទី២៣ ខែមេសា ឆ្នាំ២០១២ ចាប់ផ្តើមពីវេលាម៉ោងប្រាំបួនព្រឹក។ បង្គាប់ឲ្យអនុរក្សមន្ទីរឃុំឃាំងនាំខ្លួនជនជាប់ចោទទាំងបីរូបទៅកាន់មន្ទីរឃុំឃាំងនៃ អ.វ.ត.ក វិញ។ ហើយនិងឲ្យនាំពួកគាត់មកកាន់បន្ទប់សវនាការនេះ នៅព្រឹកថ្ងៃចន្ទ ទី២៣ ខែមេសា ឆ្នាំ២០១២ ឲ្យបានមុនម៉ោងប្រាំបួនព្រឹក។

សម្រាកចុះ៕

**ក្រឡាបញ្ជី៖**

សូមក្រោកឈរ!

*(សវនាការផ្អាកនៅម៉ោង ០៩:៤១នាទី)*